# <u>សេចក្តីប្រកាសព័ត៌មានរួម</u>

## ការប្រារព្ធយុទ្ធនាការ ១៦ថ្ងៃ នៃភាពសកម្មនិយមប្រឆាំងអំពើហិង្សាផ្អែកលើយេនឌ័រ ក្រោមប្រធានបទ «គ្មានអំពើហិង្សាលើស្ត្រី និងក្មេងស្រីដើម្បីសេដ្ឋកិច្ច និងយុត្តិធម៌សង្គម»

## រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣

យើងខ្ញុំជាក្រុមអង្គការសង្គមស៊ីវិលចំនួន២១ស្ថាប័ន មានដូចជា សមាគម សហជីព និងអង្គការមិនមែនរដ្ឋាភិបាលដែលកំពុងធ្វើការងារដើម្បីលើកកម្ពស់សិទ្ធិការងារ សិទ្ធិស្ត្រី និងសមភាពយេនឌ័រនៅប្រទេសកម្ពុជាសូមជម្រាបជូនដំណឹងអំពីការរៀបចំយុទ្ធនាការ ១៦ថ្ងៃ នៃភាពសកម្មនិយមប្រឆាំងអំពើហិង្សាផ្អែកលើយេនឌ័រ (ហៅកាត់ថា «យុទ្ធនាការ១៦ថ្ងៃ») ក្រោមប្រធានបទ **«គ្មានអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដើម្បីសេដ្ឋកិច្ច និងយុត្តិធម៌សង្គម»**។

យុទ្ធនាការនេះ មានគោលបំណងដើម្បីលើកកម្ពស់ការយល់ដឹងអំពីយុទ្ធនាការ១៦ថ្ងៃ ផ្តល់ឱកាសដល់សកម្មជន ឬអ្នកការពារសិទ្ធិមនុស្សជាស្ត្រីលើកឡើងនូវបញ្ហាប្រឈមដែលពួកគេបានជួបប្រទះខណៈដែលខ្លួនអនុវត្តសិទ្ធិស្របច្បាប់ ព្រមទាំងធ្វើការជួបជុំដើម្បីថ្លែងសាររបស់ពួកគេ និងធ្វើការពិនិត្យនិងឆ្លុះបញ្ចាំងពីការទាមទាររបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រីមកពីវិស័យផ្សេងៗ និងលើកឡើងអំពីបញ្ហាប្រឈមដែលបាននឹងកំពុងកើតមានលើស្ត្រីនិងក្មេងស្រី និងជាពិសេសជំរុញឱ្យរដ្ឋាភិបាលការពារសិទ្ធិមនុស្សឱ្យបានម៉ឺងម៉ាត់ ចំពោះអ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងដោះស្រាយបញ្ហាប្រឈមរបស់ស្ត្រី និងក្មេងស្រីឱ្យមានប្រសិទ្ធភាព។

អាស្រ័យហេតុនេះ សូមជ្រាបជាព័ត៌មាន និងអញ្ជើញចូលរួមជាមួយយើងខ្ញុំក្នុងការប្រារព្ធព្រឹត្តិការណ៍នេះតាមសកម្មភាពនានាតាមរយៈប្រព័ន្ធអនឡាញ និងដោយផ្ទាល់ ដូចខាងក្រោម៖

- នៅថ្ងៃទី**២៥ ទី២៩ និងទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ និងថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣** យើងខ្ញុំនឹងរៀបចំកម្មវិធីវិទ្យុ និង/ឬការផ្សាយបន្តផ្ទាល់នៅលើទំព័រហ្វេសប៊ុកលើប្រធានបទចំនួន៤ផ្សេងៗគ្នា។
- ចាប់ពី**ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ដល់ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២៣** យើងខ្ញុំនឹងរៀបចំកម្មវិធីសំណួរ ចម្លើយនៅលើប្រព័ន្ធអនឡាញដោយផ្តោតសំខាន់លើប្រធានបទទាក់ទងនឹងយុទ្ធនាការ ១៦ ថ្ងៃរបស់យើង។
- **នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៣** យើងខ្ញុំនឹងបង្ហោះស៊ុមរូបថតយុទ្ធនាការនៅលើទំព័រហ្វេសប៊ុកដើម្បីឱ្យសាធារណជន ឬអ្នកប្រើប្រាស់អាចប្រើប្រាស់នៅលើគណនីហ្វេសប៊ុករបស់ពួកគេ។
- ចាប់ពី**ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ដល់ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២៣** យើងខ្ញុំនឹងចេញផ្សាយ កម្រងវីដេអូខ្លីចំនួន៧ជាបន្តបន្ទាប់ ដែលមានថ្ងៃរាប់ថយក្រោយ ដើម្បីផ្តល់ដំណឹងអំពីកាលបរិច្ឆេទនៃការប្រារព្ធយុទ្ធនាការ ១៦ថ្ងៃ កាន់តែរកិលជិតមកដល់ និងមានបង្ហាញអំពីតម្រូវការរបស់ស្ត្រីនិងក្មេងស្រីផងដែរ។

- **នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៣** យើងខ្ញុំនឹងចេញផ្សាយសេចក្តីថ្លែងការណ៍រួម ដែលគូសបញ្ជាក់អំពីតម្រូវការ និងសំណូមពរជាក់លាក់មួយចំនួនសម្រាប់ជូនរាជរដ្ឋាភិបាលកម្ពុជា ដើម្បីដោះស្រាយបញ្ហាប្រឈម និងបញ្ហាផ្សេងទៀតដែលស្ត្រី និងក្មេងស្រីបានជួបប្រទះ។
- **នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣** យើងខ្ញុំនឹងចេញផ្សាយវីដេអូមួយស្តីពី «សិទ្ធិស្ត្រីក្នុងការចូលរួមការងារសង្គម និងការតស៊ូមតិ»។
- នៅព្រឹក**ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣** យើងខ្ញុំនឹងរៀបចំកម្មវិធីជួបជុំផ្ទាល់ដែលមានអ្នកចូលរួមប្រមាណ៥០០នាក់ ក្រោមប្រធានបទ «គ្មានអំពើហិង្សាលើស្ត្រី និងក្មេងស្រី ដើម្បី សេដ្ឋកិច្ច និងយុត្តិធម៌សង្គម»។
- ចាប់ពី**ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣ ដល់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣** យើងខ្ញុំនឹងបន្តចេញផ្សាយវីដេអូខ្លីជាបន្តបន្ទាប់ ដែលមានលើកឡើងអំពីតម្រូវការផ្សេងៗទៀតរបស់ស្ត្រី និងក្មេងស្រី៕

**ព័ត៌មានបន្ថែម សូមទាក់ទង៖**


១. អ្នកស្រី អ៊ូ ទេពផល្លីន ទូរស័ព្ទ៖ ០១១ ៩៨៤ ៨៨៣

២. កញ្ញា កែវ ចាន់រ៉ា ទូរស័ព្ទ៖ ០៩៨ ៨៥២ ២៦០

៣. លោក លឹម បូរិន ទូរស័ព្ទ៖ ០១២ ៩០៤ ២៦៦


***បញ្ជីឈ្មោះអង្គការសង្គមស៊ីវិលសហការរៀបចំ៖**

*១. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា*

*២. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ*

*៣. សហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា*

*៤. សហព័ន្ធសហជីពកម្ពុជា*

*៥. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ*

*៦. សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា*

*៧. សមាគមកម្មករកម្ពុជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ*

*៨. សហព័ន្ធសហជីពសេរីឯករាជ្យ*

*៩. សហព័ន្ធសហជីពឯករាជ្យ*

*១០. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស*

*១១. បណ្តាញយុវជនកម្ពុជា*

*១២. អង្គការសមធម៌កម្ពុជា*

១៣. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា

១៤. អង្គការសមាគមធាងត្នោត

១៥. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

១៦. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ

១៧. អង្គការភ្លោហាន

១៨. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ

១៩. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា

២០. អង្គការអោក់សិនអេតកម្ពុជា

២១. សហព័ន្ធសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ។